ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥១៤ អ.ក
ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩
សាលក្រមលេខៈ ០០១ /២៣-ធ-
ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣

# សាលក្រមព្រហ្មទណ្ឌ
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ១០ និង ០០ នាទីព្រឹក និងប្រកាសសាលក្រមនៅថ្ងៃទី**១០ ខែមករា** ឆ្នាំ២០២៣ ដែលមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកណ្តាល

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៖ ៥១៤ អ.ក ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ ដែលមានជនជាប់ចោទៈ

**១.ឈ្មោះ** [redacted] **សារ៉ាង** ភេទប្រុស អាយុ ៣៨ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិជន្លឹង [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **គង់** "ស្លាប់" ម្តាយឈ្មោះ [redacted] **ត្រួត** "ស្លាប់" កម្រិតវប្បធម៌ ថ្នាក់ទី០៥ ថ្មី ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈគ្មាន ។ (ក្រៅឃុំ)

**២.ឈ្មោះ** [redacted] **វណ្ណៈ** ភេទប្រុស អាយុ ២២ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើត[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **ហៃ** "រស់" ម្តាយឈ្មោះ [redacted] **សៀក** "រស់" កម្រិតវប្បធម៌ ថ្នាក់ទី០៦ ថ្មី ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈគ្មាន។ (ក្រៅឃុំ)

**៣.ឈ្មោះ** [redacted] **រ៉ាវី** ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតនៅភូ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **យឿន** "រស់" ម្តាយឈ្មោះ [redacted] **គ្រឿន** "រស់" កម្រិតវប្បធម៌ ថ្នាក់ទី០៨ ថ្មី ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈ គ្មាន។ (ក្រៅឃុំ)

**៤.ឈ្មោះ** [redacted] **ចន្ថា ហៅ ក្រឹម** ភេទប្រុស អាយុ ២៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] **ថន** "រស់"

ម្តាយឈ្មោះ [redacted] ជឿន "រស់" កម្រិតវប្បធម៌ ថ្នាក់ទី០៦ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការៈគ្មាន។ (ក្រៅឃុំ)

ត្រូវជាប់ចោទពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះឈ្មោះ [redacted] សុំ ស្ថិតនៅភូមិកោរទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **២១៨ នៃក្រមព្រហ្មទណ្ឌ។**

ដោយមានមេធាវីលោក [redacted] លោក [redacted] លោក [redacted] លោក [redacted] ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងជាមេធាវីនៃ **ក្រុមហ៊ុនមេធាវី ខេ អិន ស៊ី & អាសូស៊ីអេត** មានការិយាល័យ អគារលេខ ១១៥៩ អគារB២ ផ្លូវជាតិលេខ២ ភូមិព្រែកតានូ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ជាមេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] **សារ៉ាង** ភេទប្រុស អាយុ ៣៨ ឆ្នាំ។

**-ជនរងគ្រោះ៖**

១. ឈ្មោះ [redacted] **សារ៉ាង** ភេទប្រុស អាយុ ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិជន្លឹង ឃុំរកាជន្លឹង ស្រុកខ្សាចកណ្តាល ខេត្តកណ្តាល។

២. ឈ្មោះ [redacted] **វណ្ណៈ** ភេទប្រុស អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

**-សាក្សី៖**

ឈ្មោះ [redacted] **សារុំ** ភេទប្រុស អាយុ ៣៩ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិជន្លឹង ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

ឈ្មោះ [redacted] **ម៉េងហុង** ភេទប្រុស អាយុ ២១ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិជន្លឹង ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

ឈ្មោះ [redacted] **ធុន** ភេទប្រុស អាយុ ៣១ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៖ ១០៨៧ ដកសព ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តកណ្តាល។

-**បានឃើញ** ដីកាដំណោះស្រាយលេខ៖ ១២៩៣ ដក.ដស/២០២២ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

-**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ ១៣១៤ ដកចត/២២ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## អង្គហេតុដែលផ្តឹងមកតុលាការមានដូចតទៅ ៖

កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៩ និង ៣០ នាទី ឈ្មោះ [redacted] សារ៉ាង បានជិះម៉ូតូឌុបឈ្មោះ [redacted] សារុំ ហើយបានឈប់ម៉ូតូនៅចិញ្ចើមផ្លូវថ្មល់និយាយទូរស័ព្ទ ស្របពេលនោះ ឈ្មោះ [redacted] **វណ្ណៈ** បានជិះម៉ូតូឌុបឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] **ភារី** ហើយស្រែកថា បុកវាទៅៗរួចក៏ជិះម៉ូតូហួសទៅឈប់នៅចំណុចមុខផ្ទះឈ្មោះ [redacted] សុំ។ ពេលនោះឈ្មោះ [redacted] **សារ៉ាង** បានប្រើឈ្មោះ [redacted] **ម៉េងហុង** ដែលជាមិត្តថា អ្វែងទៅមើលអ្នកជិះម៉ូតូមិញ និងកូនណាគេក៏ឈ្លើយម្លេះវាស្រែកដាក់

អញថាបុកវាទៅៗលីដូចនេះក៏ជិះទៅមើលឃើញឈ្មោះ[redacted]ចន្ថា ហូតខ្សែក្រវ៉ាត់ពីចង្កេះខោមកកាន់ ក៏ជិះត្រលប់មកប្រាប់ឈ្មោះ [redacted] សារ៉ាង វិញស្របពេលនោះឈ្មោះ [redacted] សារ៉ាង បានទាញយកដែកប្រហោងបួនជ្រុងមួយកំណាត់ជិះម៉ូតូជាមួយឈ្មោះ[redacted]សារុំ តែពេលមកដល់ឈ្មោះ[redacted]វណ្ណៈ និងឈ្មោះ [redacted] រ៉ាវី បានកាន់ដំបងមួយកំណាត់ម្នាក់ដែរនៅចំណុចមុខផ្ទះ[redacted]ស៊ុំ ស្ថិតនៅភូមិរកាទី១ ឃុំកោះជន្លឹង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ឯឈ្មោះ [redacted]ចន្ថា កាន់ខ្សែក្រវ៉ាត់ ពេលឃើញឈ្មោះ[redacted] សារ៉ាង ភ្លាមនោះឈ្មោះ[redacted]ចន្ថា,ឈ្មោះ[redacted]វណ្ណៈ និងឈ្មោះ[redacted]រ៉ាវី ស្ទុះចូលមកវាយឈ្មោះនេះ ចំណែកឈ្មោះនេះក៏បានយកដំបងដែកដែលកាន់នៅនឹងដៃទៅវាយឈ្មោះ [redacted] វណ្ណៈ មួយដែកប្រហោងត្រូវចំចង្កា រងរបួសនិងដួលលើដី។ បន្ទាប់មកឈ្មោះ [redacted]វណ្ណៈក៏ស្ទុះក្រោកឡើងរត់ដេញវាយឈ្មោះ[redacted]សារុំ ឯឈ្មោះ[redacted]រ៉ាវី និងឈ្មោះ[redacted]ចន្ថា បានវាយប្រតាយប្រតប់គ្នាជាមួយឈ្មោះ[redacted] សារ៉ាង ដោយឈ្មោះ [redacted] រ៉ាវី វាយឈ្មោះ[redacted]សារ៉ាង ចំនួនមួយខ្សែក្រវ៉ាត់ត្រូវចំខ្នងរងរបួស និងបានដាច់ខ្សែករមាសបាត់អត់ ០១ (មួយ) កំណាត់ទម្ងន់ ០៤ ជី ០១ ហ៊ុន រួចវាយម៉ូតូឈ្មោះ[redacted]សារ៉ាង បែលក្បាំងស្ដាំ,ចង្កៀង និងស្ពុបខាងស្ដាំបែកខូចខាត ហើយឈ្មោះ[redacted] វណ្ណៈ ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ[redacted]ចន្ថា ក៏បានរត់គេចខ្លួនបាត់។

**នាពេលសវនាការ ៖**

- **ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង បានឆ្លើយថា៖** ខ្លួនទទួលស្គាល់អង្គហេតុចោទប្រកាន់ហើយ ខ្លួនទទួលស្គាល់នៅថ្ងៃកើតហេតុឈ្មោះ [redacted]វណ្ណៈ ,ឈ្មោះ [redacted]រ៉ាវី និងឈ្មោះ [redacted]ចន្ថា បានជិះម៉ូតូរកបុកខ្លួន ខ្លួនក៏សួរនាំថា កូនអ្នកណាក៏ឈ្លើយម្ល៉េះជិះម៉ូតូរកបុកអញ ពួកវាឮដូចនេះក៏បានទាញខ្សែក្រវ៉ាត់ពីចង្កេះខោ ហើយជិះម៉ូតូត្រឡប់មកវិញ ឃើញដូចនេះខ្លួនក៏រើសដំបងដែកមកកាន់វាយត្រូវភាគីម្ខាងទៀតមិនស្គាល់ឈ្មោះ និងមិនដឹងត្រូវត្រង់ណា បណ្ដាលឱ្យដួល បន្ទាប់មកទៀតមិនដឹងភាគីម្ខាងទៀតឈ្មោះអ្វីខ្លះទេចូលមកប្រតាយប្រតប់ជាមួយខ្លួន បណ្ដាលឱ្យខ្លួនរងរបួសត្រង់ខ្នង ព្រោះត្រូវនឹងខ្សែក្រវ៉ាត់របស់ភាគីម្ខាងទៀត ។ខ្លួនសូមជម្រាបថាភាគីម្ខាងទៀតបានយកខ្សែក្រវ៉ាត់មកវាយត្រូវខ្លួនមុនបណ្ដាលឱ្យរងរបួសត្រង់ខ្នង និងដាច់ខ្សែកទើបខ្លួនប្រើដែកប្រហោងវាយតបទៅភាគីនោះវិញ ។
- **ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានឆ្លើយថា៖** ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅសមត្ថកិច្ច និងពាក្យបណ្ដឹងទុកដដែល។នៅថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូឌុបឈ្មោះ [redacted] រ៉ាវី និងឈ្មោះ[redacted]ចន្ថា មកដល់ចំណុចមុខហាងលក់ទំនិញ ២៥០០ ក៏បានឃើញឈ្មោះ [redacted] សារ៉ាង ឈប់ម៉ូតូនៅកណ្ដាលផ្លូវ រួចខ្លួនក៏បានស្រែកថា បងជៀស ម៉ូតូខ្លួនអត់ហ្វ៉ាំងប្រយ័ត្នខ្លួនបុក ។ស្រាប់តែឈ្មោះនោះ បានស្រែកជេរមកវិញថា កូនអាណាឈ្លើយម្ល៉េះ រួចក៏ពួកខ្លួនក៏ស្រែកជេរតបតវិញ ហើយពួកខ្លួនក៏បានជិះហួសទៅមកដល់ចំនុចមុខផ្ទះលោកគ្រូស៊ុំ ពួកខ្លួនក៏បានឈប់ចុះនោម ។លុះបន្តិចក្រោយមក ស្រាប់តែឃើញឈ្មោះ[redacted] សារ៉ាង និងឈ្មោះ[redacted]សារុំ បានឈប់ម៉ូតូក្បែរខ្លួន រួចឈ្មោះ[redacted]សារ៉ាង ក៏បានយកដំបងដែកមកវាយខ្លួនចំមាត់បណ្ដាលបាក់ធ្មេញមុខអស់ចំនួន០១ បែកចង្កា និងមាត់ ដេរអស់ចំនួន០៧ថ្នេរ ។មួយសន្ទុះក្រោយមកខ្លួនដឹងខ្លួនវិញ ខ្លួនបានឃើញឈ្មោះ[redacted] សារុំ ឈរក្បែរម៉ូតូ(ម៉ូតូនោះមិនដួលទេ) របស់ឈ្មោះ[redacted]សារ៉ាង ហើយខ្លួនក៏បានយកដំបងឈើរត់ដេញវាយឈ្មោះ[redacted]សារុំ តែមិនត្រូវ ដោយឈ្មោះនេះបានរត់រួច ។បន្ទាប់មកខ្លួនបានត្រលប់មកកន្លែងកើតហេតុវិញ ក៏បានស្រែកគ្នា



Scanned with CamScanner

របស់ខ្លួន ពេលនោះគ្នារបស់ខ្លួនបានរត់ចេញពីផ្ទះគ្រូសុំ ហើយពេលនោះខ្លួនពុំចាប់អារម្មណ៍ថា
ម៉ូតូរបស់ឈ្មោះ [redacted] សារ៉ាង ត្រូវអ្នកណាវាយទេ ហើយខ្លួន និងបក្សពួកក៏បានជិះម៉ូតូរត់គេចខ្លួន
ពីកន្លែងកើតហេតុបាត់ទៅ ។

- **ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] រ៉ាវី បានឆ្លើយថា៖** នៅថ្ងៃកើតហេតុ
ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] ចន្ថា និងឈ្មោះ [redacted] វណ្ណៈ ដោយឈ្មោះ [redacted] វណ្ណៈ ជាអ្នកឌុប
មកដល់ចំណុចមុខហាងលក់ទំនិញ ២៥០០ ក៏បានឃើញឈ្មោះ [redacted] សារ៉ាង ឈប់ម៉ូតូនៅ
កណ្ដាលផ្លូវរួចឈ្មោះ [redacted] វណ្ណៈ ក៏បានស្រែកថា ជៀសៗប្រយ័ត្នបុក ហើយពួកខ្លួនក៏បានជិះ
ហួសទៅមកដល់ចំណុចមុខផ្ទះលោកគ្រូសុំ ម៉ូតូពួកខ្លួនរលត់ ពួកខ្លួនក៏បានឈប់ ។លុះបន្តិច
ក្រោយមក ស្រាប់តែឃើញឈ្មោះ [redacted] សារ៉ាង និងម្នាក់ទៀតមិនស្គាល់ឈ្មោះ បានឈប់ម៉ូតូក្បែរ
ខ្លួន រួចឈ្មោះ [redacted] សារ៉ាង ក៏បានយកដំបងដែកមកវាយឈ្មោះ [redacted] វណ្ណៈ ចំមាត់បណ្ដាលបាក់
ធ្មេញមុខអស់ចំនួន០១ បែកចង្កា និងមាត់ដេរអស់ចំនួន ០៧ថ្នេរ រួចហើយឈ្មោះ [redacted] សារ៉ាង
បានបម្រុងវាយឈ្មោះ [redacted] វណ្ណៈ បន្ថែមទៀត តែខ្លួនបានរងជំនួសបណ្ដាលឱ្យត្រូវដើមដៃមួយ
ដែកទីប រួចខ្លួនក៏បានយកដំបងមករងម្ដង ខ្លួនពុំបានវាយត្រូវឈ្មោះ [redacted] សារ៉ាង នោះទេ
ហើយខ្លួនបានឃើញគ្នាខ្លួនម្នាក់ទៀតឈ្មោះ [redacted] ចន្ថា វាយប្រតាយប្រតប់ឈ្មោះ [redacted] សារ៉ាង ។
ខ្លួនបានឃើញឈ្មោះ [redacted] វណ្ណៈ ក្រោកដេញវាយឈ្មោះ [redacted] សារុំ បន្ទាប់ពីក្រោកពីសន្លប់វិញ ។
ខ្លួនពុំបានដឹងថាម៉ូតូរបស់ឈ្មោះ [redacted] សារ៉ាងត្រូវអ្នកណាវាយទេ ហើយពួកខ្លួន និងបក្សពួកក៏
បានជិះរត់គេចខ្លួនពីកន្លែងកើតហេតុបាត់ទៅ បន្ទាប់មកអ្នកភូមិបានស្រែកថាប៉ូលីសៗ ។

- **ក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចន្ថា បានឆ្លើយថា៖** នៅថ្ងៃកើតហេតុ
ខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] វណ្ណៈ ដោយឈ្មោះ [redacted] វណ្ណៈ ជាអ្នកឌុប
មកដល់មុខហាងលក់ទំនិញ ២៥០០ ក៏បានឃើញឈ្មោះ [redacted] សារ៉ាង ឈប់ម៉ូតូនៅកណ្ដាលផ្លូវ
រួចឈ្មោះ [redacted] វណ្ណៈ ក៏បានស្រែកថា ជៀសៗ ប្រយ័ត្នបុក ហើយពួកខ្លួនក៏បានជិះហួសទៅមក
ដល់ចំណុចមុខផ្ទះលោកគ្រូសុំ ម៉ូតូពួករលត់ ពួកខ្លួនក៏បានឈប់ ហើយខ្លួនបានក៏បានដកខ្សែ
ក្រវ៉ាត់ ពីចង្កេះខ្លួនមកត្រៀមទុកការពារខ្លួន ដោយខ្លាចឈ្មោះ [redacted] សារ៉ាង មកតាមរករឿង។លុះ
បន្តិចក្រោយមកស្រាប់តែឃើញឈ្មោះ [redacted] សារ៉ាង និងម្នាក់ទៀតមិនស្គាល់ឈ្មោះ បានឈប់ម៉ូតូ
ក្បែរខ្លួន រួចឈ្មោះ [redacted] សារ៉ាង ក៏បានយកដំបងដែកមកវាយឈ្មោះ [redacted] វណ្ណៈ ចំមាត់បណ្ដាល
បាក់ធ្មេញមុខអស់ចំនួន ០១បែកចង្កា និងមាត់ដេរអស់៧ថ្នេរ រួចហើយឈ្មោះ [redacted] សារ៉ាង បាន
បម្រុងវាយឈ្មោះ [redacted] វណ្ណៈ បន្ថែមទៀត តែខ្លួនបានរងជំនួសបណ្ដាលឱ្យត្រូវដើមដៃមួយដែកទីប
រួចខ្លួនក៏បានយកខ្សែក្រវ៉ាត់ វាយប្រតាយប្រតប់ជាមួយឈ្មោះ [redacted] សារ៉ាង ត្រូវខ្នងឈ្មោះនោះ
ហើយគ្នាខ្លួនម្នាក់ទៀតឈ្មោះ [redacted] រ៉ាវី ក៏បានវាយឈ្មោះ [redacted] សារ៉ាង ដែរ ។ខ្លួនបានឃើញ
ឈ្មោះ [redacted] វណ្ណៈ ក្រោកដេញវាយឈ្មោះ [redacted] សារុំ បន្ទាប់ពីក្រោកពីសន្លប់វិញ។ខ្លួនពុំបានដឹងថា
ម៉ូតូរបស់ឈ្មោះ [redacted] សារ៉ាង ត្រូវអ្នកណាវាយទេ ហើយខ្លួន និងបក្សពួកក៏បានជិះរត់គេចខ្លួនពី
កន្លែងកើតហេតុបាត់ បន្ទាប់មកអ្នកភូមិបានស្រែកថា ប៉ូលីសៗ ។

- **ក្រឡាបញ្ជីបានអានការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ម៉េងហុង នៅជំណាក់កាលមន្ត្រីនគរបាល
យុត្តិធម៌ថា ៖** កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ជាថ្ងៃសែនបុណ្យចូលឆ្នាំប្រពៃណីចិន វេលា
ម៉ោង៣រសៀល ខ្លួនបានជិះម៉ូតូមួយគ្រឿងម្នាក់ឯង ចេញពីផ្ទះទៅដើរលេង នៅក្រុមហ៊ុន ៧NG

ភូមិព្រៃចាស់ ឃុំវិហារសួគ៌ ពេលទៅដល់ខ្លួនបានជួបមិត្តភក្តិខ្លួនឈ្មោះ [redacted] ផៃ និងឈ្មោះ [redacted] រ៉ុង នៅភូមិឃុំជាមួយខ្លួនដែរ នៅទីនោះពួកគាត់មានម៉ូតូមួយគ្រឿងហើយខ្លួនក៏ដើរលេងជាមួយគាត់ ដល់ម៉ោង៧យប់ពួកខ្លួនក៏នាំគ្នាត្រឡប់មកផ្ទះវិញ នៅម៉ោង ៧កន្លះយប់ពួកខ្លួនក៏មកដល់ចំណុច ផ្ទះគេខ្លួនមិនស្គាល់ឈ្មោះ ដោយមានមនុស្សមិនស្គាល់ឈ្មោះចំនួន៣នាក់ ព្រោះយប់ងងឹត ជិះពីទិសខាងកើតទៅខាងលិចបញ្ច្រាសទិសជាមួយម៉ូតូខ្លួន លុះខ្លួនជិះម៉ូតូហួសចំនុចនេះប្រហែល ១០ម៉ែត្រ ក៏ឃើញឈ្មោះ [redacted] សារ៉ាង និងឈ្មោះ រ៉ំ នៅភូមិឃុំជាមួយខ្លួនដែលពួកគាត់មានម៉ូតូមួយគ្រឿងកំពុងឈប់ម៉ូតូនៅលើចិញ្ចើមផ្លូវថ្នល់ ពេលឃើញពួកខ្លួនឈ្មោះ [redacted] សារ៉ាង បានហៅខ្លួន និងប្រាប់ថាអាប្អូនហ្អែងទៅមើលមើលអ្នកណាគេថាឱ្យអញមិញ ឯខ្លួនបានជិះមិត្តភក្តិខ្លួនក៏ជិះម៉ូតូត្រឡប់ក្រោយទៅតាមមើលមនុស្ស៣នាក់នោះ នៅដល់មុខផ្ទះឈ្មោះ [redacted] មឿន(ប្តី ប្រពន្ធ) នៅភូមិកោទី១ ក៏ឃើញមនុស្សទាំង៣នាក់នេះឈរនៅលើផ្លូវថ្នល់ខ្លួនក៏ឃើញមនុស្សម្នាក់នោះបានហូតខ្សែក្រវ៉ាត់ពីចង្កេះមកកាន់ហាក់ដូចជាប្រុងប្រៀបចាំជាស្រេច ឃើញដូច្នេះពួកខ្លួនក៏ត្រឡប់មកវិញប្រាប់ឈ្មោះ [redacted] សារ៉ាង ថាពួកវាឈរនៅមុខផ្ទះឈ្មោះ [redacted] មឿន ពួកវាមកកាន់ខ្សែក្រវ៉ាត់ទៀតមក ភ្លាមនោះឈ្មោះ [redacted] សារ៉ាង និងឈ្មោះ រ៉ំ ក៏ជិះម៉ូតូនៅមុខផ្ទះឈ្មោះ [redacted] មឿន ខ្លួនមិនដឹងថាឈ្មោះ [redacted] សារ៉ាង មានកាន់វត្ថុអ្វីនៅឬអត់ទេ ចំណែកពួកខ្លួនក៏ទៅតាមពីក្រោយដែរ ពេលខ្លួនទៅដល់ចំណុចផ្លូវកោងខាងជើងផ្ទះឈ្មោះ [redacted] មឿន ក៏ឮសូរគេវាយគ្នា ដូចផាំងៗ នៅមុខផ្ទះឈ្មោះ [redacted] មឿន នោះតែយប់ងងឹតមើលមិនឃើញ មិនដឹងថាអ្នកណាវាយអ្នកណា ឬយ៉ាងម៉េចខ្លះទេ ពួកខ្លួនក៏ត្រឡប់ក្រោយទៅផ្ទះ មិនដឹងថានៅទីនោះមានរឿងអ្វីខ្លះទៀតឡើយ ។

- **ក្រឡាបញ្ជីបានអានការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សារុំ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ៖** នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ខ្លួនរួមជាមួយមិត្តភក្តិខ្លួនឈ្មោះ [redacted] យ៉ាង ភេទប្រុស ឈ្មោះ [redacted] សារ៉ាង ភេទប្រុស និងអ្នកខ្លះទៀតនៅភូមិឃុំជាមួយខ្លួនដែរបានហូបស្រាបៀរនៅផ្ទះរបស់ឈ្មោះ [redacted] យ៉ាង រហូតដល់ម៉ោងប្រហែលមួយរសៀលខ្លួននិងមិត្តភក្តិខ្លួននេះបានជិះម៉ូតូទៅច្រៀងខារ៉ាអូខេនៅក្នុងក្រុមហ៊ុន7NG រហូតដល់ម៉ោង ៧យប់ ពួកខ្លួនក៏ត្រលប់មកផ្ទះវិញ ដោយឈ្មោះ [redacted] សារ៉ាង ជិះម៉ូតូរបស់ខ្លួនម៉ាកហុងដាសេ ១២៥ ពណ៌ខ្មៅ សេរី២០១៩ ឌុបខ្លួនមកដល់ភូមិកោទី២ ឃុំកោជន្លីង មិត្តភក្តិរបស់ខ្លួនប៉ុន្មានម៉ូតូទៀតនោះបានចូលលេងផ្ទះអ្នកភូមិនៅទីនោះ ឯខ្លួននិងឈ្មោះ [redacted] សារ៉ាង បានមកផ្ទះមុន នៅម៉ោង ៧ កន្លះ នាទី ពួកខ្លួនក៏មកដល់ចំនុចផ្ទះឈ្មោះ ថន ជាជាងផ្សារដែកនៅភូមិកោទី១ ឃុំកោជន្លីង ឯឈ្មោះ [redacted] សារ៉ាង បានឈប់ម៉ូតូនៅលើចិញ្ចើមផ្លូវថ្នល់ ស្របពេលនោះក៏ឃើញម៉ូតូ១គ្រឿងមិនស្គាល់ម៉ាកជិះដោយមនុស្ស៣នាក់ជាក្មេងស្ទាវខ្លួន មើលមិនស្គាល់ បានជិះពីទិសខាងកើតមក ពេលឃើញពួកខ្លួនមនុស្សម្នាក់ក្នុងចំណោមមនុស្ស៣នាក់នោះបានស្រែកថា បុកចុយម្រាយ ឥលូវហើយរួចក៏ជិះម៉ូតូហួសទៅទិសខាងលិចទៅ ពេលនោះក៏ឃើញក្មេងៗជិះម៉ូតូចំនួន២គ្រឿងពីទិសខាងលិចមកប្រាប់ពួកខ្លួនថាពួវ៉ាងខ្លួនឃើញអាបីនាក់នោះដោះខ្សែក្រវ៉ាត់ឈរនៅកែងផ្ទះលោកគ្រូ សុំ មិនដឹងថាចាំវៃអ្នកណាទេរួចក្មេងៗនេះក៏ជិះម៉ូតូទៅទិសខាងកើតបាត់ទៅ ភ្លាមនោះឈ្មោះ [redacted] សារ៉ាង បានទាញយកដែលប្រហោងមួយកំណាត់ពីមុខផ្ទះរបស់ឈ្មោះ ថន កាន់ជិះម៉ូតូឌុបខ្លួនទៅរកសួរនាំក្មេងស្ទាវទាំង៣នាក់នោះ ពេលទៅដល់មុខផ្ទះរបស់លោកគ្រូ [redacted] សុំ ក៏ឃើញក្មេងទាំងបីនាក់នេះឈរនៅទីនោះមាន២នាក់កាន់ដំបង១ម្នាក់ ឯម្នាក់ទៀតប្រហែលជាកាន់ខ្សែក្រវ៉ាត់

ហាក់ដូចជាត្រៀមខ្លួនរួចស្រេច គ្រាន់តែឃើញពួកខ្លួនទៅដល់ភ្លាមពួកវាបានស្ទុះចេញមកឯពួកខ្លួន ក៏ចុះពីលើម៉ូតូ ពេលនោះបានព្រួតវាយទៅលើឈ្មោះ [redacted] សារ៉ាង ខ្លួនមិនដឹងថាវាយយ៉ាងម៉េចខ្លះទេ បានបន្តិចខ្លួនក៏ត្រលប់ទៅវិញ បាត់អ្នកទាំងបីនោះ ឃើញឈ្មោះ [redacted] សារ៉ាង រងរបួសលើខ្នង បែកក្បាល និងស្អុបម៉ូតូ និងជាក់បាត់ខ្សែកមាសមួយកំណាត់ទៀត ។

- <u>**ក្រឡាបញ្ជីបានអានការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] ធុន នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ៖**</u> ខ្លួនឃើញឈ្មោះ រ៉ាង កំពុងតែវាយគ្នាជាមួយមនុស្សប្រុង២នាក់ទៀត ប៉ុន្តែខ្លួនមិនស្គាល់ទេ ដោយឈ្មោះ រ៉ាង បានកាន់ដែលប្រហោង០១ ឯមនុស្ស២នាក់ទៀតបានចាប់ជ្រៀងដែកជាមួយឈ្មោះ រ៉ាង ឃើញដូច្នេះ ខ្លួនក៏ចូលទៅឃាត់និងចាប់យកដែកនឹងចេញ ព្រមទាំងប្រាប់ថា ប៉ុណ្ណឹងបានហើយឈប់វាយគ្នាទៅ ។បន្ទាប់មកក៏បែកគ្នា រួចមនុស្សចំនួន០២នាក់នោះដើរចេញភ្លាមតែឃើញមនុស្ស២នក់ាមិនដឹងយកអ្វីនោះទេទៅវាយម៉ូតូរបស់ឈ្មោះ រ៉ាង ។ក្នុងពេលនោះ ខ្លួនក៏ឃើញខ្សែកមាសចំនួន១កំណាត់ជ្រុះនៅទីនោះ ខ្លួនបានរើសខ្សែកនេះទៅឱ្យឈ្មោះ មឿន ជាប្រពន្ធរបស់លោកគ្រូ [redacted] ស៊ុំ តែខ្លួនមិនដឹងថាខ្សែកជារបស់អ្នកណាទេ ។
- <u>**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន**</u> ក្រោយពីបានសួរដេញដោលនាពេលសវនាការ និងផ្អែកលើភស្តុតាង ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង ,ឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៩ និង៣០នាទី ពិតប្រាកដមែន។
- <u>**មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] សារ៉ាង បានធ្វើសេចក្តីសន្និដ្ឋាន៖**</u> សរុបសេចក្តីមកយើងអាចសន្និដ្ឋានថា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៩ និង៣០នាទី នៅចំណុចមុខផ្ទះឈ្មោះ [redacted] ស៊ុំ ស្ថិតនៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ពិតជាមានករណីហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ដែលបង្កឡើងដោយបក្សពួករបស់ឈ្មោះ [redacted] វណ្ណៈ ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា ពិតប្រាកដមែន និងពុំមានពិរុទ្ធភាពមកលើកូនក្តីខ្លួនឈ្មោះ [redacted] សារ៉ាង នោះទេ ។ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] សារ៉ាង ជាជនជាប់ចោទនៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ សូមស្នើសុំ តុលាការមេត្តាសម្រេចឱ្យឈ្មោះ [redacted] សារ៉ាង រួចផុតពីបទចោទពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចមុខផ្ទះឈ្មោះ [redacted] ស៊ុំ ស្ថិតនៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ជាបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ និងផ្តន្ទាទោសឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា តាមកំណត់ច្បាប់ ។
- <u>**សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង៖**</u> ខ្លួនសំណូមពរដល់តុលាការជួយបន្ធូរបន្ថយទោសដល់ខ្លួនផង។
- ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

- ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
- ក្រោយពីបានពិនិត្យលើភស្តុតាង
- ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. ផ្អែកតាមកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ,ឯកសារភស្តុតាងដែលមានក្នុងសំណុំរឿង ធៀបជាមួយនឹងចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង នៅគ្រប់ដំណាក់កាលទាំងអស់បង្ហាញឱ្យឃើញថា អង្គហេតុទាំងឡាយដែលតំណាងអយ្យការបានបើកការចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] សារ៉ាង, ឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា ដែលបានបញ្ជូនមកជំនុំជម្រះ គឺអាចកំណត់ពីអត្ថិភាពនៃអង្គហេតុពិត ដែលតុលាការជំនុំជម្រះត្រូវវាយតម្លៃអំពីពិរុទ្ធភាពរបស់ជនជាប់ចោទដោយផ្អែកលើភស្តុតាង ។

២. ចំពោះជនជាប់ចោទឈ្មោះ [redacted] **សារ៉ាង** ភេទប្រុស អាយុ៣៨ ឆ្នាំ ត្រូវបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះឈ្មោះ [redacted] សុំ ស្ថិតនៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការពិនិត្យឃើញថានៅពេលសវនាការជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនបានយកដែកប្រហោងទៅវាយឈ្មោះ [redacted] វណ្ណៈ និងបានវាយប្រតាយប្រតប់ជាមួយឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា ធៀបទៅនឹងចម្លើយរបស់ជននេះដដែល នៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលអយ្យការ និងនៅដំណាក់កាលចៅក្រមស៊ើបសួរ រួមជាមួយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងអាចវាយតម្លៃបានថា អំពើរបស់ជនជាប់ចោទរូបនេះបានបំពេញជាតុសត្យានុម័ត នៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ហើយពុំមានជាតុផ្សំបង្កើតបានជាស្ថានភាពនៃការការពារខ្លួនស្របច្បាប់នោះឡើយនៅក្នុងករណីនេះ ហើយជនជាប់ចោទរូបនេះមិនមែនជាអនីតិជន ឬជនវិបល្លាសស្មារតីនោះទេ ហេតុនេះអំពើរបស់ជនជាប់ចោទក៏បានបំពេញជាតុអត្តនោម័តនៃបទល្មើសខាងលើផងដែរ ហើយដោយផ្អែកតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ដែលជាជាតុនីត្យានុកូល ឃើញថា អំពើខាងលើបានបំពេញជាតុផ្សំគ្រប់គ្រាន់នៃបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៣. ចំពោះជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ២២ ឆ្នាំ ត្រូវបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះឈ្មោះ [redacted] សុំ ស្ថិតនៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការពិនិត្យឃើញថា ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង និងសាក្សីឈ្មោះ [redacted] ម៉េងហុង ,ឈ្មោះ [redacted] សារុំ បានឆ្លើយប្រហាក់ប្រហែលគ្នាថាបានឃើញជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ បានដោះខ្សែក្រវ៉ាត់ហើយបានវាយទៅឈ្មោះ [redacted] សារ៉ាង រួមជាមួយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ ភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នា និងចម្លើយរបស់ជនជាប់ចោទរូបនេះដែលបានឆ្លើយនៅគ្រប់ដំណាក់កាលទាំងអស់ អាចវាយតម្លៃបានថា អំពើរបស់ជនជាប់ចោទរូបនេះបានបំពេញជាតុសត្យានុម័ត នៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ហើយជនជាប់ចោទរូបនេះមិនមែនជាអ

នីតិជន ឬជនវិបល្លាសស្មារតីនោះទេ ហេតុនេះអំពើរបស់ជនជាប់ចោទក៏បានបំពេញជាតុអត្តនោម័តនៃបទល្មើសខាងលើផងដែរ ហើយដោយផ្អែកតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ដែលជាជាតុនីត្យានុកូល ឃើញថា អំពើខាងលើបានបំពេញជាតុផ្សំគ្រប់គ្រាន់នៃបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៤. ចំពោះជនជាប់ចោទឈ្មោះ [redacted] រ៉ាវី ភេទប្រុស អាយុ២១ ឆ្នាំ ត្រូវបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះឈ្មោះ [redacted] សុំ ស្ថិតនៅភូមិរកាទី១ ឃុំកោះដន្លឹង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការពិនិត្យឃើញថា ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង និងសាក្សី បានឆ្លើយប្រហាក់ប្រហែលគ្នាថាបានឃើញជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា បានដោះខ្សែក្រវ៉ាត់ហើយឈនិងបានវាយទៅឈ្មោះ [redacted] សារ៉ាង រួចរត់គេចខ្លួនបាត់ទៅ រួមជាមួយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងអាចវាយតម្លៃបានថា អំពើរបស់ជនជាប់ចោទរូបនេះបានបំពេញជាតុសត្យានុម័ត នៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ហើយជនជាប់ចោទរូបនេះមិនមែនជាអនីតិជន ឬជនវិបល្លាសស្មារតីនោះទេ ហេតុនេះអំពើរបស់ជនជាប់ចោទក៏បានបំពេញជាតុអត្តនោម័តនៃបទល្មើសខាងលើផងដែរ ហើយដោយផ្អែកតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ដែលជាជាតុនីត្យានុកូល ឃើញថា អំពើខាងលើបានបំពេញជាតុផ្សំគ្រប់គ្រាន់នៃបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៥. ចំពោះជនជាប់ចោទឈ្មោះ [redacted] ចន្ថា ភេទប្រុស អាយុ២៨ ឆ្នាំ ត្រូវបានចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចមុខផ្ទះឈ្មោះ [redacted] សុំ ស្ថិតនៅភូមិរកាទី១ ឃុំកោះដន្លឹង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ តុលាការពិនិត្យឃើញថា ដោយផ្អែកតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារ៉ាង និងសាក្សី បានឆ្លើយប្រហាក់ប្រហែលគ្នាថាបានឃើញជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ,ឈ្មោះ [redacted] រ៉ាវី និងឈ្មោះ [redacted] ចន្ថា បានដោះខ្សែក្រវ៉ាត់ហើយឈនិងបានវាយទៅឈ្មោះ [redacted] សារ៉ាង រួចរត់គេចខ្លួនបាត់ទៅ រួមជាមួយកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ភស្តុតាងផ្សេងៗដែលមានក្នុងសំណុំរឿងអាចវាយតម្លៃបានថា អំពើរបស់ជនជាប់ចោទរូបនេះបានបំពេញជាតុសត្យានុម័ត នៃបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ហើយជនជាប់ចោទរូបនេះមិនមែនជាអនីតិជន ឬជនវិបល្លាសស្មារតីនោះទេ ហេតុនេះអំពើរបស់ជនជាប់ចោទក៏បានបំពេញជាតុអត្តនោម័តនៃបទល្មើសខាងលើផងដែរ ហើយដោយផ្អែកតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ដែលជាជាតុនីត្យានុកូល ឃើញថា អំពើខាងលើបានបំពេញជាតុផ្សំគ្រប់គ្រាន់នៃបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស តាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ។

៦. **យល់ឃើញថា** តំណាងអយ្យការបានធ្វើការសន្និដ្ឋានលើសំណុំរឿងព្រហ្មទណ្ឌលេខ **៥១៤ អ.ក** ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សារ៉ាង, ឈ្មោះ** [redacted] **វណ្ណៈ ,ឈ្មោះ** [redacted] **រ៉ាវី និងឈ្មោះ** [redacted] **ចន្ថា ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិរកាទី១ ឃុំកោះដន្លឹង ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩។

**៧. យល់ឃើញថា** ដោយជនជាប់ចោទឈ្មោះ [redacted]**សារ៉ាង** ភេទប្រុស អាយុ៣៨ ឆ្នាំ បានឆ្លើយសារភាព គ្រប់ទង្វើរបស់ខ្លួនដែលអាចបង្ហាញពីស្មារតីសហការណ៍ផ្តល់ការពិតដល់សវនាការ ហេតុនេះគប្បីតុលាការ ពិចារណាលើកម្រិតនៃការផ្តន្ទាទោសលើជនជាប់ចោទ ។

**៨. យល់ឃើញថា** ដោយដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ មិនបង្ហាញខ្លួន ពេលសវនាការ ហេតុនេះតុលាការមិនអាចស្តាប់ការអះអាងចំពោះការទាមទារ ឬមិនទាមទារសំណងផ្នែក រដ្ឋប្បវេណីនោះទេ ដោយឡែកចំពោះដើមបណ្តឹងរដ្ឋប្បវេណី និងជនជាប់ចោទឈ្មោះ [redacted] សារ៉ាង មិនបាន បង្ហាញឆន្ទៈទាមទារសំណងនៅពេលសវនាការឡើយ ។

## ហេតុដូច្នេះ សម្រេចសេចក្តី

ផ្តន្ទាទោសលើជនជាប់ចោទ៖

ឈ្មោះ [redacted]**សារ៉ាង** ភេទប្រុស អាយុ ៣៨ ឆ្នាំ ,ឈ្មោះ [redacted]**វណ្ណៈ** ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] **រ៉ាវី** ភេទប្រុស អាយុ ២១ឆ្នាំ , ឈ្មោះ [redacted]ចន្ថា ភេទប្រុស អាយុ ២៣ឆ្នាំ ដូចមានកំណត់ក្នុង អត្តសញ្ញាណខាងលើដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់រយៈពេល **២(ពីរ)ឆ្នាំ** ពីបទ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិរកាទី១ ឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលជាបទល្មើសព្រហ្មទណ្ឌមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិ មាត្រា ២១៩ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះ ជំនុំជម្រះនៅថ្ងៃទី**២៩** ខែធ្នូ ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី**១០ ខែមករា** ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារ៉ាង និង កំបាំងមុខជនជាប់ចោទ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហៃ វណ្ណៈ ។

***ទុកសិទ្ធិប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។***

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

(បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម)

ថ្ងៃអង្គារ ០៤ រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៖

កណ្តាល, ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner